# ការហៅដ៏ទេវភាពនៃអ្នកផ្សព្វផ្សាយសាសនាម្នាក់ៗ

*អែលឌើរ រ៉ នណាល់ អេ រ៉ាស់បេនដ៍*
*ពីគណៈប្រធាននៃពួកចិតសិបនាក់*

អរុណសួស្ដីបងប្អូនប្រុសនៃបព្វជិតភាពជាទីស្រឡាញ់របស់ខ្ញុំ។ នៅយប់នេះ ខ្ញុំចង់និយាយអំពីការបំរើជាអ្នកផ្សព្វផ្សាយសាសនា។ ខ្ញុំសូមផ្ដោតមតិរបស់ខ្ញុំទៅលើក្រុមដ៏ធំនៃពួកយុវជនដែលកាន់បព្វជិតភាពអើរ៉ុនដែលប្រមូលផ្ដុំគ្នានៅទូទាំងពិភពលោក និងចំពោះឪពុក និងពួកអ្នកដឹកនាំបព្វជិតភាពរបស់ពួកគេដែលមើលខុសត្រូវលើពួកគេ។

កិច្ចការផ្សព្វផ្សាយគឺជាប្រធានបទដែលខ្ញុំស្រឡាញ់បំផុត ក៏ជាប្រធានបទដែលគ្រប់សមាជិកនៃកូរ៉ុមទាំងប្រាំបីនៃពួកចិតសិបនាក់ដែលព្រះអម្ចាស់បានតែងតាំងឱ្យទៅ «ចាត់គេឱ្យទៅមុនទ្រង់មួយគូៗក្នុងគ្រប់ក្រុងគ្រប់កន្លែងដែលទ្រង់គិតយាងទៅ»។ 1 កិច្ចការផ្សព្វផ្សាយសាសនា គឺសំខាន់ណាស់ចំពោះសាសនាចក្រ និងជាពរជ័យជួយសង្គ្រោះជីវិតអ្នកទាំងឡាយណា ដែលទទួលយកសារលិខិតពីកិច្ចការនេះ។

នៅពេលដែលលោកថៅហ្វាយបង្រៀននៅក្នុងចំណោមមនុស្ស នោះទ្រង់បានហៅអ្នកនេសាទនៅកាលីឡេឱ្យទុកអួន របស់ពួកគេ ហើយដើរប្រកាសតាមទ្រង់ថា៖ «ខ្ញុំនឹងតាំងអ្នកឱ្យជាអ្នកនេសាទមនុស្សវិញ»។ 2 ព្រះអម្ចាស់បានពង្រីកការហៅទាំងនោះចំពោះបុរសដែលមានចិត្តរាបទាប ដែលតាមរយៈពួកគេ នោះអ្នកដទៃនឹងបានឮអំពីសេចក្ដីពិតនៃដំណឹងល្អ និងឱ្យមករកទ្រង់។

នៅខែ មិថុនា ឆ្នាំ 1837 ព្យាការីយ៉ូសែប ស្ម៊ីធ បានហៅប្រធានហ៊ីប៊ឺ ស៊ី ឃីមប៊ល ជាសាវកឱ្យទៅបំរើបេសកកម្ម នៅប្រទេសអង់គ្លេស។ ការហៅរបស់អែលឌើរ ឃីមប៊ល បានកើតឡើង នៅពេលដែលពួកគាត់ទាំងពីរនាក់បានអង្គុយ នៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់ និងយ៉ូសែប ស្ម៊ីធ ដែលមានសិទ្ធិអំណាចដ៏ទេវភាពថា៖ «បងប្រុស ហ៊ីប៊ឺ ព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានខ្សឹបប្រាប់ខ្ញុំថា៖ ‵ទុកឱ្យអ្នកបំរើរបស់យើង ហ៊ីប៊ឺ ទៅប្រទេសអង់គ្លេស និងប្រកាសដំណឹងល្អរបស់យើង ហើយបើកទ្វារនៃសេចក្ដីសង្គ្រោះដល់ជាតិសាសន៍នោះ»។ 3

ការខ្សឹបប្រាប់ពីព្រះវិញ្ញាណគឺជាឧទាហរណ៍មួយអំពីរបៀបដែលការហៅបានធ្លាក់មកលើពួកអ្នកបំរើរបស់ព្រះអម្ចាស់ ដើម្បីបញ្ជូនពួកអ្នកផ្សព្វផ្សាយសាសនាទៅកាន់តំបន់ការងាររបស់ពួកគេ។

នៅសព្វថ្ងៃនេះពួកអ្នកផ្សព្វផ្សាយសាសនាចេញទៅជាគូៗ ដូចដែលត្រូវបានតែងតាំងដោយព្រះអម្ចាស់ ដោយមាននូវសារលិខិតដូចគ្នា ព្រមជាមួយនឹងការហៅឱ្យបំរើដ៏ទេវភាពដូចគ្នាមកពីព្យាការីនៃព្រះ។ ព្យាការីរបស់យើង ប្រធានថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា ការហៅឱ្យបំរើទាំងនោះគឺជា៖

«ឱកាសផ្សព្វផ្សាយសាសនានៃជីវិតនេះជារបស់អ្នក។ ពរជ័យដ៏នៅអស់កល្បជានិច្ចកំពុងតែរង់ចាំអ្នក។ ឱកាសរបស់អ្នកគឺជាអភ័យឯកសិទ្ធិពុំមែនឈរមើលនោះទេ ប៉ុន្តែគឺដើម្បីចូលរួមចំណែកនៅក្នុងការបំរើនៃបព្វជិតភាព»។ 4

ប្អូនប្រុសបព្វជិតភាពអើរ៉ុនជាទីស្រឡាញ់របស់ខ្ញុំអើយ ឱកាសនេះគឺជារបស់អ្នក។ តើអ្នករួចរាល់ និងមានឆន្ទៈដើម្បីធ្វើនូវតួនាទីរបស់អ្នកហើយឬនៅ? ព្រះអម្ចាស់ ត្រូវការយុវជនដែលមានសមត្ថភាពគ្រប់រូប ដើម្បីរៀបចំខ្លួន និងតាំងចិត្តជាថ្មីចាប់ផ្ដើមពីយប់នេះ ដើម្បីមានភាពសក្ដិសមចំពោះការហៅពីព្យាការីនៃព្រះ ដើម្បីបំរើបេសកកម្មមួយ។

ខ្ញុំនៅចងចាំអំពីសេចក្ដីរីករាយដ៏ជាទីស្រឡាញ់ដែលក្រុមគ្រួសាររបស់យើងទាំងមូលមាន នៅពេលកូនរបស់យើងពីរនាក់បានទទួលការហៅរបស់ពួកគេឱ្យទៅបំរើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងនោះ។ ភាពរីករាយ និងការចូលរួមចំណែកបានបំពេញនៅក្នុងដួងចិត្តរបស់យើង នៅពេលពួកគេបានបើកសំបុត្រពិសេសមួយមកពីព្យាការីរបស់ព្រះ។ កូនស្រីរបស់យើងជេណេស្សា ត្រូវបានហៅឱ្យបំរើនៅបេសកកម្មម៉ិឈីហ្គែនខេត្រូត កូនប្រុសរបស់យើងឈ្មោះ គ្រីស្ទាន ត្រូវបានហៅឱ្យបំរើនៅបេសកកម្មរុស្ស៊ីម៉ូស្គូខាងត្បូង។ នោះគឺជាបទពិសោធន៍នៃការបន្ទាបខ្លួន និងភាពរីករាយដែលកើតឡើងក្នុងពេលព្រមគ្នា!

នៅពេលដែលស៊ិស្ទើរ រ៉ាសបាន ហើយខ្ញុំមានឱកាសធ្វើជាអធិបតីនៅបេសកកម្មញូវយ៉កញូវយ៉កខាងជើង កាលពីពីរបីឆ្នាំមុន ខ្ញុំមានការស្ញប់ស្ញែងណាស់នៅពេលដែលពួកអ្នកផ្សព្វផ្សាយសាសនាបានមកដល់ទីក្រុងញូវយ៉ក។

នៅពេលដែលខ្ញុំសម្ភាសពួកគេ នៅក្នុងថ្ងៃដំបូងដែលពួកគេបានមកដល់បេសកកម្ម ខ្ញុំមាននូវអារម្មណ៍នៃអំណរគុណដ៏ជ្រាលជ្រៅសម្រាប់ពួកអ្នកផ្សព្វផ្សាយសាសនាម្នាក់ៗ។ ខ្ញុំមានអារម្មណ៍ថា ការហៅរបស់ពួកគេឱ្យមកបំរើនៅបេសកកម្មរបស់យើង គឺជាជោគវាសនាដ៏ទេវភាពចំពោះពួកគេ និងសម្រាប់ខ្ញុំ ក្នុងនាមជាប្រធានបេសកកម្មរបស់ពួកគេ។

បន្ទាប់ពីបានបញ្ចប់កិច្ចការបេសកកម្មរបស់យើង ខ្ញុំត្រូវបានហៅដោយប្រធាន ហ្គរដុន ប៊ី ហ៊ីងគ្លី ឱ្យបំរើក្នុងក្រុមពួកចិតសិបនាក់ក្នុងសាសនាចក្រ។ ផ្នែកមួយនៃការបំពាក់បំប៉នក្នុងនាមជាពួកអ្នកមានសិទ្ធិអំណាចទូទៅ ត្រូវបានរួមទាំងឱកាសមួយដើម្បីអង្គុយជាមួយនឹងសមាជិកនៃពួកដប់ពីរនាក់ នៅពេលដែលពួកគាត់ធ្វើការតែងតាំងពួកអ្នកផ្សព្វផ្សាយសាសនាឱ្យបំរើនៅក្នុងបេសកកម្មជាង 300 បេសកកម្មនៃសាសនាចក្រដ៏អស្ចារ្យនេះ។

ដោយមានការលើកទឹកចិត្ត និងការអនុញ្ញាតពីប្រធាន ហិនរី ប៊ី អាវរីង ខ្ញុំសូមលើកឡើងនូវបទពិសោធ

មួយ ដែលជាបទពិសោធន៍ដ៏ពិសេសដែលខ្ញុំមានជាច្រើនឆ្នាំទៅហើយ កាលពីខ្ញុំនៅជាសមាជិកនៃពួកដប់ពីរនាក់។ សាវកមួយរូបៗមានកូនសោនៃនគរ និងប្រើប្រាស់កូនសោទាំងនេះតាមទិសដៅ និងការចាត់តាំងមកអំពីប្រធាននៃសាសនាចក្រ។ អែលឌើរ អារវីងបានកំពុងតែរៀបចំពួកអ្នកផ្សព្វផ្សាយសាសនាឱ្យទៅក្នុងតំបន់ដែលពួកគេបានបំរើដែលជាផ្នែកមួយនៃការបំពាក់បំប៉នរបស់ខ្ញុំ ដែលត្រូវបានអញ្ជើញឱ្យធ្វើការសង្កេតមើល។

ខ្ញុំបានចូលរួមជាមួយនឹងអែលឌើរ អារវីង កាលពីព្រឹកព្រលឹមមួយនៅក្នុងបន្ទប់ ដែលមានកុំព្យូទ័រដែលមានអេក្រង់ធំៗជាច្រើន ដែលត្រូវបានរៀបចំសំរាប់ធ្វើកិច្ចការនេះ។ ក៏មានបុគ្គលិកមួយចំនួនមកពីការិយាល័យផ្សព្វផ្សាយសាសនា ដែលត្រូវបានចាត់តាំងឱ្យជួយនៅក្នុងថ្ងៃនោះ។

ដំបូង យើងបានលុតជង្គង់ចុះនៅក្នុងការអធិស្ឋាន។ ខ្ញុំចងចាំការឃើញអែលឌើរ អារវីង បានប្រើប្រាស់ពាក្យពេចន៍ដ៏មានន័យ បួងសួងឱ្យព្រះអម្ចាស់ប្រសិទ្ធិពរជ័យឱ្យលោកបានដឹង «យ៉ាងឥតខ្ចោះ» នូវកន្លែងដែលពួកអ្នកផ្សព្វផ្សាយសាសនាត្រូវបញ្ជូនទៅ។ ពាក្យ«យ៉ាងឥតខ្ចោះ» និយាយច្រើនអំពីសេចក្តីជំនឿដែល អែលឌើរ អារវីង បានលើកឡើងនៅថ្ងៃនោះ។

នៅពេលដែលដំណើរការត្រូវបានបញ្ចប់ រូបភាពនៃអ្នកផ្សព្វផ្សាសាសនាដែលត្រូវចាត់តាំងនឹងផុសឡើងនៅលើអេក្រង់ នៃកុំព្យូទ័រមួយ។ នៅពេលដែលរូបភាពនីមួយៗលេចនៅចំពីមុខខ្ញុំ ចំពោះខ្ញុំ វាហាក់ដូចជាពួកអ្នកផ្សព្វផ្សាយសាសនារូបនោះ បាននៅក្នុងបន្ទប់ជាមួយនឹងយើងដែរ។ អែលឌើរ អារវីង បន្ទាប់មកនឹងស្វាគមន៍ដល់អ្នកផ្សព្វផ្សាយសាសនាដោយ សន្តានចិត្ត និងសម្លេងដ៏ទន់ភ្លន់របស់គាត់៖ «អរុណសួស្តី អែលឌើរ រៀ ឬស៊ិស្ទើរ យ៉ាង។ តើអ្នកសុខសប្បាយទេនៅថ្ងៃនេះ?»

គាត់បានប្រាប់ខ្ញុំថា នៅក្នុងគំនិតរបស់គាត់ គាត់ចូលចិត្តគិតអំពីថាតើពួកអ្នកផ្សព្វផ្សាយសាសនា ត្រូវបញ្ចប់បេសកកម្មរបស់ពួកគេនៅកន្លែងណា។ ការធ្វើបែបនេះនឹងជួយឱ្យគាត់ដឹងថាត្រូវចាត់តាំងពួកគេនៅកន្លែងណា។ អែលឌើរ អារវីង បន្ទាប់មកសិក្សាអំពីយោបល់មកពីប៊ីស្សព និងប្រធានស្តេក កំណត់សំគាល់ផ្នែកវេជ្ជសាស្ត្រ និងបញ្ហាផ្សេងៗទៀត ដែលទាក់ទងនឹងអ្នកផ្សព្វផ្សាយសាសនាម្នាក់ៗ។

បន្ទាប់មកគាត់បានមើលទៅអេក្រង់ផ្សេងទៀត ដែលមានដាក់នូវតំបន់បេសកកម្មនៅទូទាំងពិភពលោក។ នៅទីបំផុត នៅពេលគាត់ត្រូវបានបំផុសដោយព្រះវិញ្ញាណ នោះគាត់នឹងធ្វើការចាត់តាំងអ្នកផ្សព្វផ្សាយសាសនា ទៅតំបន់ការងាររបស់ពួកគេ។

ខ្ញុំបានរៀនពីពួកដប់ពីរនាក់ដទៃទៀត ថាវិធីសាស្ត្រជាទូទៅនេះគឺជារឿងធម្មតាជារៀងរាល់សប្តាហ៍ នៅពេលពួកសាវកនៃព្រះអម្ចាស់ចាត់ចែងពួកអ្នកផ្សព្វផ្សាយសាសនាជាឱ្យទៅបំរើនៅទូទាំងពិភពលោក។

ការបំរើជាអ្នកផ្សព្វផ្សាយសាសនានៅក្នុងប្រទេសរបស់ខ្ញុំផ្ទាល់នៅបេសកកម្មអ៊ីស្ទីនស្តេតស៍ ជាច្រើនឆ្នាំកន្លងទៅហើយ ខ្ញុំត្រូវបានជំរុញដោយបទពិសោធន៍ដ៏ជ្រាលជ្រៅនោះ។ ផងដែរ ការបំរើជាប្រធានបេសកកម្ម ខ្ញុំមានអំណរគុណចំពោះការធ្វើជាសាក្សីនៅក្នុងដួងចិត្តរបស់ខ្ញុំថា ពួកអ្នកផ្សព្វផ្សាយសាសនាដែលខ្ញុំបានទទួលឱ្យបំរើនៅក្នុងទីក្រុងញូវយ៉ក គឺត្រូវបានបញ្ជូនមកកាន់ខ្ញុំតាមរយៈវិវរណៈ។

បន្ទាប់ពីការចាត់តាំងពួកអ្នកផ្សព្វផ្សាយសាសនាពីរបីនាក់ អែលឌើរ អារវីង បានងាកមកកាន់ខ្ញុំ នៅពេលគាត់ សញ្ជឹងគិតអំពីអ្នកផ្សព្វផ្សាយសាសនាដ៏ពិសេសម្នាក់ ហើយនិយាយថា៖ «មែនហើយ បងប្រុស រ៉ាសបាន តើបងប្រុសគិតថា អ្នកផ្សព្វផ្សាយសាសនាម្នាក់នេះគួរតែទៅកន្លែងណា?» ខ្ញុំទើបតែចាប់ផ្តើម! ខ្ញុំបានផ្តល់យោបល់ យ៉ាងស្ងប់ស្ងាត់ដល់អែលឌើរ អារវីង ថា ខ្ញុំពុំដឹងទេ ហើយខ្ញុំក៏ពុំដឹងថា ខ្ញុំគួរតែដឹងដែរនោះទេ! គាត់បានមើលមកខ្ញុំដោយចំៗ ហើយបានឆ្លើយយ៉ាងសាមញ្ញថា៖ «បងប្រុស រ៉ាសបាន សូមយកចិត្តទុកដាក់ ហើយបងប្រុសនឹងអាចដឹងបានផងដែរ!» ពាក្យសំដីនេះ បានធ្វើឱ្យខ្ញុំទាញកៅអីខិតកាន់តែជិតទៅនឹងអែលឌើរ អារវីង និងអេក្រង់កុំព្យូទ័រ។ ខ្ញុំបានផ្តោតយកចិត្តទុកដាក់យ៉ាងខ្លាំង!

នៅពេលដំណើរការបានបន្តទៅមុខបានពីរបីដង អែលឌើរ អារវីង នឹងងាកមុខមកកាន់ខ្ញុំ ហើយនិយាយថា «ពិតមែនហើយ បងប្រុស រ៉ាសបាន តើអ្នកគិតថា អ្នកផ្សព្វផ្សាយសាសនាម្នាក់នេះគួរតែទៅកន្លែងណា?» ខ្ញុំរៀបរាប់ឈ្មោះបេសកកម្មមួយចំនួន ហើយអែលឌើរ អារវីង នឹងមើលមកខ្ញុំដោយគិតវែងឆ្ងាយ ហើយនិយាយថា៖ «ទេ មិនមែនបេសកកម្មនេះទេ!» បន្ទាប់មក គាត់បន្តចាត់តាំងពួកអ្នកផ្សព្វផ្សាយសាសនាទៀត ជាកន្លែងដែលគាត់ទទួលបានអារម្មណ៍បំផុសគំនិត។

នៅពេលដែលយើងជិតបញ្ចប់ការប្រជុំការចាត់តាំង នោះរូបភាពនៃពួកអ្នកផ្សព្វផ្សាយសាសនាមួយចំនួនបានលេចឡើង នៅលើអេក្រង់។ ខ្ញុំទទួលអារម្មណ៍នៃការបំផុសគំនិតដ៏ខ្លាំង ជាអារម្មណ៍បំផុសខ្លាំងជាងគេបំផុតនៅព្រឹកនោះ ថាអ្នកផ្សព្វផ្សាយសាសនាដែលមានឈ្មោះនៅពីមុខយើងគឺត្រូវចាត់តាំងឱ្យទៅបំរើនៅប្រទេសជប៉ុន។ ខ្ញុំពុំបានដឹងថា អែលឌើរ អារវីង នឹងត្រូវសួរខ្ញុំលើកនេះទៀតទេ ប៉ុន្តែគ្រាន់តែគិតថា គាត់អាចសួរ។ ជំនួសឱ្យភាពទន់ភ្លន់ និងការបន្ទាបខ្លួន ខ្ញុំនិយាយទៅកាន់គាត់ថា៖ «ប្រទេសជប៉ុន?» អែលឌើរ អារវីង ឆ្លើយភ្លាមថា៖ «ត្រឹមត្រូវហើយ ត្រូវបញ្ជូនទៅទីនោះ»។ នៅលើអេក្រង់កុំព្យូទ័របេសកកម្មប្រទេសជប៉ុនបានលេចឡើង។ ខ្ញុំបានដឹងយ៉ាងច្បាស់ថា អ្នកផ្សព្វផ្សាយសាសនាត្រូវទៅបេសកកម្មសាប៉ូរ៉ូ ប្រទេសជប៉ុន។

អែលឌើរ អារវីង ពុំបានសួរខ្ញុំថាទៅបេសកកម្មណាឱ្យច្បាស់នោះទេ ប៉ុន្តែខ្ញុំពិតជាបានចាត់តាំងអ្នកផ្សព្វផ្សាយសាសនា រូបនោះឱ្យទៅបេសកកម្មសាប៉ូរ៉ូ ប្រទេសជប៉ុន។

នៅក្នុងចិត្តខ្ញុំ ខ្ញុំទទួលការប៉ះនៃដួងចិត្ត និងមានអំណរគុណយ៉ាងខ្លាំងចំពោះព្រះអម្ចាស់ ដែលអនុញ្ញាតឱ្យខ្ញុំមាននូវបទពិសោធន៍នៃការបំផុសគំនិត ដើម្បីដឹងថាតើអ្នកផ្សព្វផ្សាយសាសនាគួរតែទៅកន្លែងណា។

នៅទីបញ្ចប់នៃការប្រជុំ អែលឌើរ អារវីង បានថ្លែងសាក្សីរបស់គាត់មកកាន់ខ្ញុំ អំពីសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះដែលមានសំរាប់អ្នកផ្សព្វផ្សាយសាសនាម្នាក់ៗ ដែលត្រូវបានចាត់តាំងទៅកាន់ពិភពលោក និងផ្សព្វផ្សាយដំណឹងល្អដែលត្រូវបានស្ដារឡើងវិញ។ គាត់បាននិយាយថា គឺដោយសារតែសេចក្ដីស្រឡាញ់ដ៏មហិមារបស់ព្រះអម្ចាស់នោះហើយ ទើបពួកអ្នកបំរើរបស់ទ្រង់ស្គាល់យុវជន និងយុវនារីអ្នកផ្សព្វផ្សាយសាសនាជាប្ដីប្រពន្ធដែលត្រូវបំរើដ៏អស្ចារ្យទាំងនេះ។ ខ្ញុំធ្វើជាសាក្សីបន្ថែមពីលើនេះថា រាល់អ្នកផ្សព្វផ្សាយសាសនាដែលត្រូវបានហៅនៅក្នុងសាសនាចក្រនេះ និងដែលត្រូវបានចាត់តាំង ឬត្រូវបានចាត់តាំងជាថ្មីម្ដងទៀត ឱ្យទៅកាន់បេសកកម្មណាមួយ គឺត្រូវបានធ្វើឡើងតាមរយៈវិវរណៈមកអំពីព្រះដ៏មានមហិទ្ធិ តាមរយៈអ្នកបំរើណាម្នាក់របស់ទ្រង់។

ខ្ញុំសូមបញ្ចប់ជាមួយនឹងពាក្យពេចន៍របស់ព្រះអម្ចាស់ទៅកាន់បងប្អូនប្រុស វិតមើរ ដែលជាអ្នកមានតួនាទីដ៏សំខាន់នៅក្នុងសម័យដើម នៃការស្ដារឡើងវិញ។ ពួកគេគឺជាសាក្សីនៃផ្ទាំងមាស និងទីបន្ទាល់ដ៏អស្ចារ្យគឺត្រូវបានកត់ត្រាបញ្ចូលនៅផ្នែកខាងមុខនៃ *ព្រះគម្ពីរមរមន*។ ពួកគេគឺជាក្រុមពួកអ្នកផ្សព្វផ្សាយសាសនាដំបូងដែលត្រូវបានហៅដោយព្រះនៅឆ្នាំ 1829 ដើម្បីផ្សព្វផ្សាយដំណឹងល្អនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ។

នៅក្នុងអារម្ភកថាកណ្ឌទី 14 នៃគោលលទ្ធិ និងសេចក្ដីសញ្ញាបានសរសេរថា៖ «ដោយពួកគេម្នាក់ៗបានទទួលទីបន្ទាល់អំពីភាពពិតត្រង់នៃកិច្ចការនោះ ទើបកូនប្រុសបីនាក់ពីត្រកូលវិតមើរ មានការបារម្ភអំពីភារកិច្ចរបស់ពួកគេនីមួយៗ»។ 5

ចំពោះយ៉ូហាន និងពេត្រុស វិតមើរ ជុញ្ញ័រ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «**ត្បិតគ្រាជាច្រើនដែលអ្នកបានប្រាថ្នាពីយើង សូមចង់ដឹងនូវអ្វីដែលមានតម្លៃបំផុតចំពោះអ្នក** »។ 6 ខ្ញុំសន្មត់ថា អ្នករាល់គ្នាជាច្រើនដែលជាយុវជន ត្រូវបានសុំឱ្យសួរខ្លួនរបស់អ្នកនូវសំណួរដូចគ្នានោះ។ នេះគឺជាចម្លើយ។

**« ហើយឥឡូវនេះមើលចុះ យើងមានបន្ទូលមកកាន់អ្នកថា ការណ៍ដែលនឹងមានតម្លៃបំផុតចំពោះអ្នកគឺដើម្បីផ្សាយប្រាប់ពីការប្រែចិត្តដល់ប្រជាជននេះ ដើម្បីឱ្យអ្នកអាចនាំព្រលឹងទាំងឡាយមករកយើង ដើម្បីឱ្យអ្នកអាចសំរាកជាមួយពួកគេ នៅក្នុងនគរនៃព្រះវរបិតារបស់យើង»**។ 7

នៅក្នុងគ្រានេះនៃជីវិតរបស់អ្នក ពួកយុវជនយុវនារីវ័យក្មេងអើយ ការហៅឱ្យបំរើបេសកកម្មមកពីព្រះអម្ចាស់ គឺជាកិច្ចការដ៏មានសារៈសំខាន់បំផុតដែលអ្នកអាចធ្វើ។ សូមរៀបចំខ្លួនពីពេលឥឡូវនេះ សូមរស់នៅដោយសុចរិត សូមរៀនពីក្រុមគ្រួសារ និងពួកអ្នកដឹកនាំសាសនាចក្ររបស់អ្នក។ ចូរមក ហើយ

ចូលរួមជាមួយនឹងយើងនៅក្នុងការ ស្ថាបនានគរព្រះនៅលើផែនដី---ទទួលយកឱកាសដ៏ទេវភាពរបស់អ្នក នៅក្នុង «ចលនាដ៏មហិមា»។ 8

នេះគឺជាការអធិស្ឋានដ៏រាបទាបរបស់ខ្ញុំ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. លូកា 10:1។
2. ម៉ាថាយ 4:19។
3. Teachings of the Presidents of the Church Joseph Smith សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ឆ្នាំ 2007 ទំព័រ 327។
4. «Jesus′ Charge to Teach All Nations Still Applies» LDS Church News ឆ្នាំ 1995 ទំព័រ 04/08/95-1។
5. គោលលទ្ធិ និងសេចក្ដីសញ្ញា 95:6។
6. កថាកណ្ឌទី 14 នៃ គោលលទ្ធិ និងសេចក្ដីសញ្ញា។
7. គោលលទ្ធិ និងសេចក្ដីសញ្ញា 15:4។
8. គោលលទ្ធិ និងសេចក្ដីសញ្ញា 15:6។
9. គោលលទ្ធិ និងសេចក្ដីសញ្ញា 128:22។